ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ ២១ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៥

# រាជកិច្ច

រួមមាន៖

- ច្បាប់
- ក្រម - ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

# មាតិកា

## I-ទីស្តីការគណៈរដ្ឋមន្ត្រី

### ១- អនុក្រឹត្យ


១២-៦-១៩៩៩ - អនុក្រឹត្យ លេខ ៤៧ អនក្រ បក ស្តីពីការបង្កើតទិវាអនាម័យ- បរិដ្ឋាន ជាតិ ៨៧០

១២-៦-១៩៩៩ - អនុក្រឹត្យ លេខ ៤៨ អនក្រ បក ស្តីពីការកែសំរួលមាត្រា ៥នៃ អនុក្រឹត្យ លេខ ០៤ អនក្រ ចុះថ្ងៃទី ០៥-០១-១៩៩៩ ស្តីពីការបង្កើតគណៈកម្មការជាតិទទួលបន្ទុក ការងារជំនួយយោធាពីបរទេស ៨៧១

១៥-៦-១៩៩៩ - អនុក្រឹត្យ លេខ ៤៩ អនក្រ បក ស្តីពីការបំពេញបន្ថែមតំណាងរដ្ឋលេខាធិការកិច្ចការនារីជាសមាជិកគណៈកម្មាធិការ ឥណទាន សំរាប់អភិវឌ្ឍន៍ជនបទ ៨៧៣

១៣-៦-១៩៩៩ - អនុក្រឹត្យលេខ ៦៩ អនក្រ តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៨៧៤


### ២- សេចក្តីសំរេច


១២-៦-១៩៩៩ - សេចក្តីសំរេច លេខ ៤៣ សសរ ស្តីពីការផ្ទេរសិទ្ធិ ៨៧៦


## II-ការងារបណ្តាក្រសួង

# គ

## ៥ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ ជនបទ

### ប្រកាស

១២-៦-១៩៩៥ ប្រកាស លេខ ១៣២២អជប ស្តីពីការតែងតាំងមន្ត្រីរាជការ ៨៩០

# I-ទីស្តីការគណៈរដ្ឋមន្ត្រី

## ១ - អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ១៩៩៥

### អនុក្រឹត្យលេខ ៤៧ អនក្រ . បក

### ស្តីពីការបង្កើតទិវាអនាម័យបរិដ្ឋានជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងគ្រប់គ្រងបរិដ្ឋាន

### សំរេច

**មាត្រា១** :បង្កើតទិវាចលនាប្រជាពលរដ្ឋចូលរួមធ្វើពលកម្មអនាម័យ និងលំអសោភ័ណភាពទីក្រុង ទីប្រជុំជន ជនបទ ភូមិដ្ឋាន វត្តអារាម សាលារៀន មន្ទីរពេទ្យ រោងចក្រ សហគ្រាស ទីផ្សារ មជ្ឈមណ្ឌលសេដ្ឋកិច្ច ដើម្បីលើកកំពស់គុណភាពបរិដ្ឋានរបស់ប្រទេសជាតិ ហៅថា «ទិវាអនាម័យបរិដ្ឋានជាតិ» ដែលត្រូវប្រារព្ធធ្វើនៅថ្ងៃទី ២៣ វិច្ឆិកា ជារៀងរាល់ឆ្នាំ ។

**មាត្រា២** : ទិសដៅ នៃទិវាអនាម័យបរិដ្ឋានជាតិ គឺចលនាប្រជារាស្ត្រ ព្រះសង្ឃ កងយោធពលខេមរភូមិន្ទ នគរបាល អ្នករាជការគ្រប់ផ្នែកគ្រប់ថ្នាក់ សិស្ស និស្សិត គ្រប់ភូមិសិក្សាចូលរួមទាំង ស្មារតី ទាំងសំភារៈ

ក្នុងបំណងបំបាត់អោយខាងតែបានភាពក្រខក់ និងសំរាម កាក សំណល់ផ្សេងៗ
ដើម្បីកែលំអបរិស្ថានប្រែក្លាយព្រះរាជាណាចក្រកម្ពុជា ជាប្រទេសគ្រប
ដណ្ដប់ដោយរុក្ខជាតិខៀវស្រងាត់ ផ្ដល់នូវពណ៌ស្រស់ស្អាត សុខភាព
ជីវភាពរស់នៅរបស់ ពលរដ្ឋប្រកបដោយអនាម័យបរិដ្ឋានល្អ ។

**មាត្រា៣** : ពលរដ្ឋទាំងពីរភេទ ព្រះសង្ឃ កងយោធពលខេមរភូមិន្ទ នគរបាល អ្នករាជការគ្រប់ផ្នែក
គ្រប់ថ្នាក់សិស្សនិស្សិត មានកាតព្វកិច្ចធ្វើពលកម្មអនាម័យ រៀបចំសួនច្បារ
សួនលំហែ ដើម្បីអបអរសាទរទិវាអនាម័យបរិស្ថានជាតិថ្ងៃទី ២៣ វិច្ឆិកា ។

**មាត្រា៤** : ក្រសួងមហាផ្ទៃមានភារកិច្ចណែនាំដល់ខេត្ត- ក្រុង
កំណត់ទីកន្លែងដាក់ស្នៀតសំរាម ការធ្វើពលកម្មអនាម័យ រៀបចំសួនឧទ្យាន
ទន្ទឹមនឹងការដាំដើមឈើអោយបានច្រើនបំផុត និងទទួលបានប្រសិទ្ធភាពខ្ពស់ ។

**មាត្រា៥** : ក្រសួងគ្រប់គ្រងបរិស្ថាន មានភារកិច្ចណែនាំបច្ចេកទេស និងសហការជាមួយគណៈ
កម្មាធិការបុណ្យជាតិ និងបណ្ដាក្រសួងខេត្ត- ក្រុង ក្នុងការអនុវត្តន៍ ព្រមទាំងធ្វើរបាយ
ការណ៍ពីលទ្ធផលជាកំរិតជូនគណៈរដ្ឋមន្ត្រី ។

**មាត្រា៦** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី គណៈកម្មាធិការបុណ្យជាតិ រដ្ឋមន្ត្រី
រដ្ឋលេខាធិការ នៃក្រសួងស្ថាប័ន និងអភិបាលខេត្ត- ក្រុង
ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន
ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ ។

**នាយករដ្ឋមន្ត្រីទី១** **នាយករដ្ឋមន្ត្រីទី២**

...លេខា និងត្រា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

ធ្វើនៅភ្នំពេញ ថ្ងៃទី១២ ខែមិថុនា ឆ្នាំ ១៩៩៥

**ចម្លងត្រឹមត្រូវតាមច្បាប់ដើម** ... :

[illegible]

បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ ចុះថ្ងៃទី ០៥-០១-១៩៩៥ ស្ដីពីការបង្កើតគណៈកម្មការជាតិទទួលបន្ទុកការងារជំនួយយោធាពីបរទេស

តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

**សម្រេច**

មាត្រា ៩ នៃអនុក្រឹត្យ ចុះថ្ងៃទី ០៥-០១-១៩៩៥ ស្ដីពីការបង្កើតគណៈកម្មការជាតិទទួលបន្ទុកការងារជំនួយយោធាពីបរទេស

**ប្រការ ១** ត្រូវបានកែសម្រួលដូចខាងក្រោម :

ដើម្បីជាជំនួយកិច្ចការដល់គណៈកម្មការជាតិនេះ លេខាធិការដ្ឋានមួយ

ត្រូវបានបង្កើតឡើង រួមមានសមាសភាព :

- ឯកឧត្ដម ... រដ្ឋលេខាធិការក្រសួងការពារជាតិ

ប្រធាន

- លោកឧត្ដមសេនីយ៍ទោ ... ទីប្រឹក្សាក្រសួងការពារជាតិ

អនុប្រធានអចិន្ត្រៃយ៍

- លោកឧត្ដមសេនីយ៍ត្រី ... នាយខុទ្ទកាល័យយោធាក្រសួង ការពារជាតិ សមាជិកអចិន្ត្រៃយ៍

- លោកឧត្ដមសេនីយ៍ត្រី ... នាយខុទ្ទកាល័យស៊ីវិលក្រសួង ការពារជាតិ សមាជិកអចិន្ត្រៃយ៍

- លោកឧត្តមសេនីយ៍ត្រី **ឡាយ ម៉ិនសុខ** នាយក នាយកដ្ឋានទាក់ទងអន្តរជាតិក្រសួងការពារជាតិ សមាជិកអចិន្ត្រៃយ៍
- លោកស្រី **យូ អយ** ប្រធាននាយកដ្ឋានសហប្រតិបត្តិការ អន្តរជាតិក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិកអចិន្ត្រៃយ៍
- លោកវរសេនីយ៍ឯក **ម៉ៅ រដ្ឋា** នាយរងខុទ្ទកាល័យអគ្គសេនាធិការ សមាជិកអចិន្ត្រៃយ៍
- លោកវរសេនីយ៍ទោ **ឈួន ចំនួនឆាយ៉ា** នាយកការិយាល័យជំនួយបរទេស នាយកដ្ឋានទាក់ទងអន្តរជាតិក្រសួងការពារជាតិ សមាជិកអចិន្ត្រៃយ៍
- លោកវរសេនីយ៍ទោ **ពត សុខ** នាយរងក្រុមផែនការ អគ្គសេនាធិការ សមាជិកអចិន្ត្រៃយ៍
- លោក **សយ សុខា** តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និងត្រា | ហត្ថលេខា និងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

ೞೞ⊛ೞೞ

រាជធានីភ្នំពេញ ,ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៥

**អនុក្រឹត្យលេខ ៤៩ អនក្រ.បក**

**ស្តីពីការបំពេញបន្ថែមតំណាងរដ្ឋលេខាធិការដ្ឋានកិច្ចការនារី**

**ជាសមាជិកគណ:កម្មាធិការតំណាងរាស្ត្រសំរាប់អតីតយុទ្ធជនជន**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ

១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រឹត្យក្រោសបង្គាប់អោយកែសំរួលសមាសភាពរាជរដ្ឋាភិបាលលេខ នស/រកត/១០៩៤/៩៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលត្រូវបាន ប្រកាស អោយប្រើជាផ្លូវការដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ .
- យោងអនុក្រឹត្យលេខ ៣០ អនក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតគណៈ កម្មាធិការផណទានសំរាប់អភិវឌ្ឍន៍ជនបទ
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ និងរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការ ដ្ឋានកិច្ចការនារី

**សំរេច**

**មាត្រា១** : បំពេញបន្ថែមជាសមាជិកនូវតំណាងរដ្ឋលេខាធិការដ្ឋានកិច្ចការនារី ក្នុងគណៈកម្មការផណទាន សំរាប់អភិវឌ្ឍន៍ជនបទដែលបានចែងអនុក្រឹត្យលេខ ៣០ អនក្រ ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ របស់រាជរដ្ឋាភិបាលកម្ពុជា ។

**មាត្រា២** : គណៈកម្មាធិការផណទានសំរាប់អភិវឌ្ឍន៍ជនបទ«គ ជ ទាន» និងគ្រប់ក្រសួងស្ថាប័ននានា ដែលមានការពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និងត្រា | ហត្ថលេខា និងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

❀❀❀

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ១៩៩៥

**អនុក្រឹត្យលេខ ៦៩ អនក្រ តត**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យ លេខ ២៨ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង អភិបាលរងខេត្ត- ក្រុង ។
- តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៥

**សំរេច**

**មាត្រា១** : តែងតាំងលោក **ចំនួ សំអាន** ជាអភិបាលរងទី ៣ ខេត្តកំពង់ធំ ជំនួសលោក **អាំង ម៉ុនថា** ដែលត្រូវទៅបំពេញមុខងារផ្សេងទៀត ។

**មាត្រា២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងអស់លោកដែលមានឈ្មោះក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

# ២- សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី១២ខែ មិថុនា ឆ្នាំ ១៩៩៥

**សេចក្តីសំរេចលេខ ៤៣ សសរ**

**ស្តីពីការផ្ទេរសិទ្ធិ**

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាស អោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមការងារចាំបាច់ ។

**សំរេច**

**ប្រការ១** : ត្រូវបានផ្ទេរភារកិច្ចជូន ឯកឧត្តម**គាត ឈន់** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងឱកាសដែលឯកឧត្តម**ចន្ទា ម៉ូលីចន្ទា** អញ្ជើញទៅបំពេញបេសកកម្មនៅឯបរទេស ចាប់ពីថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ១៩៩៥ រហូតដល់ពេលឯកឧត្តមអញ្ជើញត្រឡប់វិញ ។

**ប្រការ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងឯកឧត្តម**គាត ឈន់** ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយ ព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និងត្រា | ហត្ថលេខា និងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

# II-ការិយាល័យក្រសួង

## ១ - ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ប្រកាស**

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ១៩៩៥

**ប្រកាសលេខ ១៩២ ប្រក.សហវ, ថ**

ស្តីពីការបង្វែរឥណទាន

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាស អោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស, រកត ១០៩៤, ៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួល សមាភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០១ នស ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាស អោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ១០ នស, ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីអំពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ០៩ អនក្រ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ ស្តីអំពីការបែងចែកឥណទានតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ០០៤ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទានផ្ទៃក្នុងតាមជំពូក ប្រការ កថាខ័ណ្ឌ និង

វាក្យខ័ណ្ឌ ជូនបណ្តាក្រសួងតាមឥណទានចែងក្នុងច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥

- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកាឆ្នាំ ១៩៩៥
- តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ៩៣៤ សហវ ចុះថ្ងៃទី ១២ ខែ ៦ ឆ្នាំ ១៩៩៥

**សំរេច**

**ប្រការ១** : ត្រូវបានប្រតិបត្តិនៅក្នុងវង្វង់ថវិការបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងថវិកាឆ្នាំ ១៩៩៥ នូវការបង្វែរឥណទានដូចបានបញ្ជាក់ខាងក្រោម :

ឯកតា : ពាន់រៀល

| ជំពូក | ប្រការ | កថាខ័ណ្ឌ | វាក្យខ័ណ្ឌ | កំណត់ត្រាក់ចំណាយ | ស្ថានភាពឥណទានដើមឆ្នាំ | ការកែប្រែឥណទាន | | ស្ថានភាពឥណទានថ្មី |
|---|---|---|---|---|---|---|---|---|
| | | | | | | កើន | ថយ | |
| 10 | 03 | 02 | | ការបង្វែរពីជំពូក១០<br>ប្រាក់បំណាច់ផ្សេងៗ | 30,000,00 | | 20,000,00<br>20,000,00 | 10,000,00 |
| 10 | 01 | 07 | 03 | អ្នកជំនួយការជំពូក ១០<br>អ្នកជំនួយការ | 25,000,00 | 20,000,00<br>20,000,00 | | 45,000,00 |

**ប្រការ២** : ស្ថាប័នដែលមានការពាក់ព័ន្ធរបស់ក្រសួង ឬ ខេត្ត- ក្រុង ជាអ្នកទទួលបន្ទុករៀងៗខ្លួន ក្នុងការអនុវត្តន៍សេចក្តីសំរេចនេះ ។

ជ, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អនុរដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

**គាយ ច័ន្ទ**

## ២- ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

**ប្រកាស**

រាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ១៩៩៥

**ប្រកាសលេខ ១២០/៩៥ ពម ប្រក**

ស្តីពីការផ្ទេរចូលរបស់មន្ត្រីរាជការ

******

–បានឃើញ ព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

–បានឃើញសេចក្តីសំរេច លេខ ៨៩ សសរ ចុះថ្ងៃទី ១០–១០ –១៩៨៣ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីប្រព័ន្ធបៀវត្សកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ

–យោងតាមសំណើសុំផ្លាស់ប្តូរកន្លែងធ្វើការ ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៩៥

–ពិនិត្យលើសភាពការណ៍ជាក់ស្តែងរបស់សាមីខ្លួន ។

**សំរេច**

**ប្រការ ១** :យល់ព្រម និង ទទួលស្គាល់អោយ លោកស្រី **ប្លាក់ ធីតា** បុគ្គលិក ការិយាល័យវិទ្យុ នៃមន្ទីរពតិមានខេត្តបាត់ដំបង មកបំរើការងារនៅអគ្គនាយកដ្ឋានវិទ្យុជាតិ នៃក្រសួងពតិមានវិញ ។

**ប្រការ ២** :ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេង ។ របស់សាមីខ្លួន ត្រូវបានទទួលនៅអគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា ចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៥ នេះតទៅ ។

**ប្រការ ៣** :អគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា នាយកដ្ឋានបុគ្គលិក រដ្ឋបាល នាយកដ្ឋានគណនេយ្យ ផែនការ ហិរញ្ញកិច្ច មន្ទីរពតិមាន ខេត្តបាត់ដំបង និងសាមីខ្លួនត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**អៀង ម៉ូលី**

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៩៥

**ប្រកាសលេខ ១២១/៩៥ ពម ប្រក**

– បានឃើញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសានបញ្ញត្តិមាត្រាទី ១៣៩។

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ **១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា** ។

– បានឃើញច្បាប់សារពត៌មាន ត្រូវបានរដ្ឋសភា នៃរដ្ឋកម្ពុជាអនុម័តនា សម័យ ប្រជុំវិសាមញ្ញ ថ្ងៃទី០៦ ខែ មេសា ឆ្នាំ ១៩៩២ នីតិកាលទី ១ ។

– បានឃើញសេចក្តីបញ្ជាក់របស់តុលាការក្រុងភ្នំពេញលេខ ២២៧ រប ៩២១/៩៥ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩៥ ហត្ថលេខាដោយចៅក្រម **ថោង អូល** ស្តីពី នៅពេលសាលក្រមលេខ ៣៣ក ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៩៩៥ មិនទាន់ចូលជាស្ថាពរការសែត «**ឧត្តមគតិខ្មែរ**» អាច ចេញផ្សាយបន្តបាន ។

– បានឃើញប្រកាសសំរេច ៥៧/៩៥ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

**សំរេច**

**ប្រការ ១** : អនុញ្ញាតអោយសារពត៌មានឈ្មោះ «**ឧត្តមគតិខ្មែរ**» ចេញផ្សាយបន្តឡើងវិញដោយ មានលោក **ឆន់ ម៉ុនលី** ជាចាងហ្វាងការផ្សាយរហូតដល់មានសាលក្រមពីឧទ្ធរណ៍ ចូលជាធរមាន ។

**ប្រការ ២** : ខ្លឹមសារអត្ថបទ និងសកម្មភាពផ្សព្វផ្សាយត្រូវស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៣** : គោរពច្បាប់សារពត៌មាន គោលការណ៍ក្រមសីលធម៌អ្នកកាសែត និងឈរលើស្មារតី ទទួលខុសត្រូវខ្ពស់ លើវិជ្ជាជីវៈរបស់ខ្លួន និងស្នើប្រគល់កាសែតចំនួន ១៥ ច្បាប់ រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

**ប្រការ ៤** : លោក **ឆន់ ម៉ុនលី** ចាងហ្វាងការផ្សាយ និង នាយកដ្ឋានមណ្ឌលពត៌មាន នៃ ក្រសួងពត៌មានត្រូវអនុវត្តនូវប្រកាសនេះ ។

**ប្រការ ៥** : ប្រកាសនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

**ខៀវ កាញារីទ្ធ**

## ៣—ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**ប្រកាស**

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៩៥

**ប្រកាសលេខ ៦៦៧ អយក ប្រក**

ស្តីពីការកំណត់មណ្ឌលប្រឡងសញ្ញាប័ត្រមធ្យមសិក្សាកំរិត ១

*******

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

– បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេច **នរោត្តមសីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

– បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០–៧–៩៤

– បានឃើញក្រឹត្យ ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ។

– បានឃើញលិខិតខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រីលេខ ២២៣៧ សជណ.អវ ចុះថ្ងៃទី ១៩ វិច្ឆិកា ១៩៩០ ស្តីការប្តូរឈ្មោះសាលារៀនចំណេះទូទៅ ។

– បានឃើញប្រកាសក្រសួងលេខ ២៣២៨ អរ.ចទប ចុះថ្ងៃទី ១៧–៥–១៩៨០ ស្តីពីការបង្កើត[illegible]មានការប្រឡងសញ្ញាប័ត្រកំរិតសិក្សាទី ២ ។

– បានឃើញប្រក[illegible]របស់រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា លេខ ៦៥៤អយក.ប្រកចុះ[illegible]ទី ០៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ស្តីពីការរៀបចំ និងការ

ប្រព្រឹត្តិទៅនៃការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាកំរិត ១ ។

-យោងសំណើ របស់មន្ទីរអប់រំ យុវជននិង កីឡា ខេត្ត-ក្រុង ស្តីពីការសុំបើក មណ្ឌលប្រឡងសញ្ញាប័ត្រមធ្យមសិក្សាកំរិត ១ តាមខេត្តក្រុង ។

**សំរេច**

**ប្រការ ១:** មណ្ឌលប្រឡងសញ្ញាប័ត្រមធ្យមសិក្សាកំរិត ១ ចំណេះទូទៅ និងបំពេញវិជ្ជាលើកទី ១ សម័យប្រឡង ១៣ កក្កដា ១៩៩៥ ត្រូវកំណត់ដូចតទៅ :

**I-រាជធានីភ្នំពេញ មាន ១៩ មណ្ឌល :**

| | |
|---|---|
| ១-មណ្ឌល វិទ្យាល័យ ព្រះស៊ីសុវត្ថិ | មាន ៥០ បន្ទប់ សំរាប់ចំណេះទូទៅ |
| ២-មណ្ឌល បឋមសិក្សា នរោត្តម | មាន ២៨ បន្ទប់ សំរាប់ចំណេះទូទៅ |
| ៣-មណ្ឌល អនុវិទ្យាល័យចតុមុខ | មាន ២៧ បន្ទប់ ក្នុងនោះបំពេញវិជ្ជា ០២បន្ទប់ |
| ៤-មណ្ឌល វិទ្យាល័យបូស្សីកែវ | មាន ២៥ បន្ទប់ សំរាប់ចំណេះទូទៅ |
| ៥-មណ្ឌល អនុវិទ្យាល័យវត្តភ្នំ | មាន ២៤ បន្ទប់ សំរាប់ចំណេះទូទៅ |
| ៦-មណ្ឌល វិទ្យាល័យបាក់ទូក | មាន ៦៥ បន្ទប់ សំរាប់ចំណេះទូទៅ |
| ៧-មណ្ឌល បឋមសិក្សា បាក់ទូក | មាន ៣៥ បន្ទប់ សំរាប់ចំណេះទូទៅ |
| ៨-មណ្ឌល វិទ្យាល័យឥន្ទ្រទេវី | មាន ៤០ បន្ទប់ សំរាប់ចំណេះទូទៅ |
| ៩-មណ្ឌលបឋមសិក្សាទួលគោក | មាន ៣៧ បន្ទប់សំរាប់ចំណេះទូទៅ |
| ១០-មណ្ឌលវិទ្យាល័យសន្ធរម៉ុក | មាន ៥៦ បន្ទប់ សំរាប់ចំណេះទូទៅ |
| ១១-មណ្ឌល គរុកោសល្យភូមិភាគ | មាន ៣៧ បន្ទប់ សំរាប់ចំណេះទូទៅ |
| ១២-មណ្ឌល វិទ្យាល័យ ជម្ពូវ័ន | មាន ២៨ បន្ទប់ សំរាប់ចំណេះទូទៅ |
| ១៣-មណ្ឌលវិទ្យាល័យបឹងត្របែក | មាន ៤០ បន្ទប់ សំរាប់ចំណេះទូទៅ |
| ១៤-មណ្ឌល បឋមសិក្សា ជ័យជំនះ | មាន ២៥ បន្ទប់ សំរាប់ចំណេះទូទៅ |
| ១៥-មណ្ឌលវិទ្យាល័យច្បារអំពៅ | មាន ៣៩ បន្ទប់ សំរាប់ចំណេះទូទៅ |
| ១៦-មណ្ឌលវិទ្យាល័យទួលទំពូង | មាន ៤០ បន្ទប់ សំរាប់ចំណេះទូទៅ |
| ១៧-មណ្ឌលបឋមសិក្សា ដូនពេញ | មាន ៣៤ បន្ទប់ សំរាប់ចំណេះទូទៅ |
| ១៨-មណ្ឌលវិទ្យាល័យ ព្រះយុគន្ធរ | មាន ៣៥ បន្ទប់ សំរាប់ចំណេះទូទៅ |

| | |
|---|---|
| ១៩–មណ្ឌលអនុវិទ្យាល័យ វត្តកោះ | មាន ៤៤ បន្ទប់ សំរាប់ចំណេះទូទៅ |

## II - ខេត្តកណ្តាល

| | |
|---|---|
| ១–មណ្ឌលវិទ្យាល័យកំពង់ភ្នំ | មាន ១៦ បន្ទប់ សំរាប់ចំណេះទូទៅ |
| ២–មណ្ឌលវិទ្យាល័យទេពប្រណម្យ | មាន ២៥ បន្ទប់ សំរាប់ចំណេះទូទៅ |
| ៣–មណ្ឌលវិទ្យាល័យព្រែកតាឡុង | មាន ២៨ បន្ទប់ សំរាប់ចំណេះទូទៅ |
| ៤–មណ្ឌលវិទ្យាល័យកំពង់កន្ទួត | មាន ២០ បន្ទប់ សំរាប់ចំណេះទូទៅ |
| ៥–មណ្ឌលវិទ្យាល័យស្អាង | មាន ១៤ បន្ទប់ សំរាប់ចំណេះទូទៅ |
| ៦–មណ្ឌលអនុវិទ្យាល័យព្រះសីហនុវរ្ម័ន | មាន ២៤ បន្ទប់ សំរាប់ចំណេះទូទៅ |
| ៧–មណ្ឌលអនុវិទ្យាល័យព្រែកឯង | មាន ២១ បន្ទប់ សំរាប់ចំណេះទូទៅ |
| ៨–មណ្ឌលវិទ្យាល័យជ័យវរ្ម័នទី ៧ | មាន ២៨ បន្ទប់ សំរាប់ចំណេះទូទៅ |
| ៩–មណ្ឌលអនុវិទ្យាល័យបែកចាន | មាន ១៧ បន្ទប់ សំរាប់ចំណេះទូទៅ |
| –អនុមណ្ឌលបឋមសិក្សាកុយតិប | មាន ១២ បន្ទប់ សំរាប់ចំណេះទូទៅ |
| ១០–មណ្ឌលអនុវិទ្យាល័យសិរីមង្គល | មាន ១៧ បន្ទប់ សំរាប់ចំណេះទូទៅ |
| ១១–មណ្ឌលវិទ្យាល័យព្រែកអញ្ចាញ | មាន ១៨ បន្ទប់ សំរាប់ចំណេះទូទៅ |
| ១២–មណ្ឌលវិទ្យាល័យទឹកឃ្លាំង | មាន ១៣ បន្ទប់ សំរាប់ចំណេះទូទៅ |
| –អនុមណ្ឌលបឋមសិក្សាទឹកឃ្លាំង | មាន ០៦ បន្ទប់ សំរាប់ចំណេះទូទៅ |
| ១៣–មណ្ឌល វិទ្យាល័យខ្សាច់កណ្តាល | មាន ១៤ បន្ទប់ សំរាប់ចំណេះទូទៅ |
| ១៤–មណ្ឌលអនុវិទ្យាល័យព្រះសីហនុរាជ | មាន ៣១ បន្ទប់ សំរាប់ចំណេះទូទៅ |
| ១៥–មណ្ឌលវិទ្យាល័យតាខ្មៅ | មាន ២០ បន្ទប់ សំរាប់ចំណេះទូទៅ |
| ១៦–មណ្ឌលបឋមសិក្សា ក្រពើហា | មាន ១៦ បន្ទប់ សំរាប់ចំណេះទូទៅ |
| ១៧–មណ្ឌល បឋមសិក្សា តាខ្មៅ | មាន ១៥ បន្ទប់ សំរាប់ចំណេះទូទៅ |

## III– ខេត្តតាកែវមាន ០៧ មណ្ឌល :

| | |
|---|---|
| ១–មណ្ឌល វិទ្យាល័យតាកែវ | មាន ២៨ បន្ទប់ សំរាប់ចំណេះទូទៅ |
| ២–មណ្ឌលវិទ្យាល័យ ព្រៃល្វា | មាន ២២ បន្ទប់ សំរាប់ចំណេះទូទៅ |
| ៣–មណ្ឌលវិទ្យាល័យបាទី | មាន ២០ បន្ទប់ សំរាប់ចំណេះទូទៅ |
| ៤–មណ្ឌលវិទ្យាល័យសម្តេចឱ | មាន ១៥ បន្ទប់ សំរាប់ចំណេះទូទៅ |

| | |
|---|---|
| ៥–មណ្ឌលវិទ្យាល័យ ១ ឧសភា | មាន ២៧ បន្ទប់ សំរាប់ចំណេះទូទៅ |
| ៦–មណ្ឌលវិទ្យាល័យ ព្រៃសណ្ដែក | មាន ១៨ បន្ទប់ សំរាប់ចំណេះទូទៅ |
| ៧–មណ្ឌលវិទ្យាល័យទម្លាប់ | មាន ២២ បន្ទប់ សំរាប់ចំណេះទូទៅ |

## IV–ខេត្តកំពត មាន ០៥ មណ្ឌល

| | |
|---|---|
| ១–មណ្ឌល វិទ្យាល័យព្រះរាជសម្ភារ | មាន ២៧ បន្ទប់ សំរាប់ចំនេះទូទៅ |
| ២–មណ្ឌលបឋមសិក្សាកំពតក្រុង | មាន ១៤ បន្ទប់ សំរាប់ចំនេះទូទៅ |
| ៣–មណ្ឌលបឋមសិក្សាសម្ដេចតា | មាន ១៩ បន្ទប់ សំរាប់ចំនេះទូទៅ |
| ៤–មណ្ឌលបឋមសិក្សាមហាសាមគ្គី | មាន ២៣បន្ទប់ សំរាប់ចំនេះទូទៅ |
| ៥–មណ្ឌលគរុកោសល្យ ខេត្ត | មាន ១១ បន្ទប់ ទូទៅក្នុងនោះមាន មានបំពេញវិជ្ជាមួយបន្ទប់ |

## V- ក្រុងព្រះសីហនុ មាន ០២ បន្ទប់

| | |
|---|---|
| ១–មណ្ឌលអនុវិទ្យាល័យសម្ដេចឳ | មាន ២២ បន្ទប់ សំរាប់ចំនេះទូទៅ |
| ២–មណ្ឌលបឋមសិក្សា ក្រុងព្រះសីហនុ | មាន ១៥ បន្ទប់ សំរាប់ចំនេះទូទៅ |

## VI - ខេត្តកំពង់ស្ពឺ មាន ០៦ មណ្ឌល

| | |
|---|---|
| ១–មណ្ឌលវិទ្យាល័យ កំពង់ស្ពឺ | មាន ១១ បន្ទប់ សំរាប់ចំនេះទូទៅ |
| ២–មណ្ឌលវិទ្យាល័យ សុខាផល្លី | មាន ១០ បន្ទប់ សំរាប់ចំនេះទូទៅ |
| ៣–មណ្ឌលអនុវិទ្យាល័យទីរួមខេត្ត | មាន ២០ បន្ទប់ សំរាប់ចំនេះទូទៅ |
| ៤–មណ្ឌលអនុវិទ្យាល័យ ចំបក់ | មាន ២១ បន្ទប់ សំរាប់ចំនេះទូទៅ |
| ៥–មណ្ឌលវិទ្យាល័យឧដុង្គ | មាន ១២ បន្ទប់ សំរាប់ចំនេះទូទៅ |
| ៦–មណ្ឌលអនុវិទ្យាល័យ ស្រង់ | មាន ២៦ បន្ទប់ សំរាប់ចំនេះទូទៅ |

## VII - ខេត្ត ព្រៃវែង មាន ១០ មណ្ឌល

| | |
|---|---|
| ១–មណ្ឌលវិទ្យាល័យ ព្រះអង្គឌួង | មាន ២៨ បន្ទប់ ក្នុងនោះបំពេញវិជ្ជា ០១ បន្ទប់ |
| ២–មណ្ឌលវិទ្យាល័យពាមរក៍ | មាន ១៩ បន្ទប់ សំរាប់ចំនេះទូទៅ |

| | |
|---|---|
| ៣–មណ្ឌលវិទ្យាល័យ មេសាង | មាន ១៥ បន្ទប់ សិក្សាចំនេះទូទៅ |
| ៤–មណ្ឌលវិទ្យាល័យបាភ្នំ | មាន ១៨ បន្ទប់ សិក្សាចំនេះទូទៅ |
| ៥–មណ្ឌល វិទ្យាល័យល្វា | មាន ១៨ បន្ទប់ សិក្សាចំនេះទូទៅ |
| ៦–មណ្ឌលវិទ្យាល័យកំពង់ត្របែក | មាន ២១ បន្ទប់ សិក្សាចំនេះទូទៅ |
| ៧–មណ្ឌលវិទ្យាល័យពារាំង | មាន ២៨ បន្ទប់ សិក្សាចំនេះទូទៅ |
| ៨–មណ្ឌលវិទ្យាល័យ ព្រែកសណ្តែក | មាន ១៦ បន្ទប់ សិក្សាចំនេះទូទៅ |
| ៩–មណ្ឌលវិទ្យាល័យកំចាយមារ | មាន ១៨ បន្ទប់ សិក្សាចំនេះទូទៅ |
| ១០–មណ្ឌលវិទ្យាល័យស្វាយអន្ទរ | មាន ១២ បន្ទប់ សិក្សាចំនេះទូទៅ |

## VIII - ខេត្ត ស្វាយរៀង មាន ០៥ មណ្ឌល :

| | |
|---|---|
| ១–មណ្ឌលវិទ្យាល័យ ស្វាយរៀង | មាន ៤៣ បន្ទប់ សិក្សាចំនេះទូទៅ |
| ២–មណ្ឌលបឋមសិក្សា ព្រះសីហនុ | មាន ២០ បន្ទប់ សិក្សាចំនេះទូទៅ |
| ៣–មណ្ឌលវិទ្យាល័យស្វាយជ្រុំ | មាន ២៧ បន្ទប់ សិក្សាចំនេះទូទៅ |
| ៤–មណ្ឌលវិទ្យាល័ រមាសហែក | មាន ២០ បន្ទប់ សិក្សាចំនេះទូទៅ |
| ៥–មណ្ឌលវិទ្យាល័យ ប្រសូតិ | មាន ១៨ បន្ទប់ សិក្សាចំនេះទូទៅ |

## IX - ខេត្តកំពង់ឆ្នាំង មាន ០២ មណ្ឌល និង ០១ អនុមណ្ឌល

| | |
|---|---|
| ១–មណ្ឌលវិទ្យាល័យ ព្រះសុរាម្រិត | មាន ២៩ បន្ទប់ សិក្សាចំនេះទូទៅ |
| ២–មណ្ឌលអនុវិទ្យាល័យ ទីរួមខេត្ត | មាន ១៥ បន្ទប់ សិក្សាចំនេះទូទៅ |
| –អនុមណ្ឌលបឋមសិក្សាតំរូវក្រុង | មាន ១៣ បន្ទប់ សិក្សាចំនេះទូទៅ |

## X - ខេត្តពោធិ៍សាត់ មាន ០៣ មណ្ឌល :

| | |
|---|---|
| ១–មណ្ឌលវិទ្យាល័យ ពោធិ៍សាត់ | មាន ២៩ បន្ទប់ សិក្សាចំនេះទូទៅ |
| ២–មណ្ឌលបឋមសិក្សាពោធិ៍សាត់ | មាន ២៥ បន្ទប់ សិក្សាចំនេះទូទៅ |
| ៣–មណ្ឌលអនុវិទ្យាល័យបាកាន | មាន ១៦ បន្ទប់ សិក្សាចំនេះទូទៅ |

**XI - ខេត្តបាត់ដំបង មាន ០៨ មណ្ឌល និង ០២ អនុមណ្ឌល :**

| | |
|---|---|
| ១–មណ្ឌលវិទ្យាល័យ បាត់ដំបង | មាន ៤១ បន្ទប់ សំរាប់ចំនេះទូទៅ |
| ២–មណ្ឌលបឋមសិក្សា ២ ធ្នូ | មាន ៤២ បន្ទប់ សំរាប់ចំនេះទូទៅ |
| ៣–មណ្ឌលវិទ្យាល័យ ស្វាយប៉ោ | មាន ៣១ បន្ទប់ សំរាប់ចំនេះទូទៅ |
| ៤–មណ្ឌលគរុកោសល្យភូមិភាគ | មាន ១៨ បន្ទប់ សំរាប់ចំនេះទូទៅ |
| ៥–មណ្ឌលបឋមសិក្សា សម្តេច ជា ស៊ីម | មាន ១៧ បន្ទប់ សំរាប់ចំនេះទូទៅ |
| ៦–មណ្ឌលអនុវិទ្យាល័យ ដីរស | មាន ១៥ បន្ទប់ សំរាប់ចំនេះទូទៅ |
| –អនុមណ្ឌលបឋមសិក្សាវត្តកំផែង | មាន ១០ បន្ទប់ សំរាប់ចំនេះទូទៅ |
| ៧–មណ្ឌលអនុវិទ្យាល័យ ទីរួមខេត្ត | មាន ២០ បន្ទប់ សំរាប់ចំនេះទូទៅ |
| ៨–មណ្ឌលបឋមសិក្សា រតនៈ | មាន ១១ បន្ទប់ សំរាប់ចំនេះទូទៅ |
| –អនុមណ្ឌលគរុកោសល្យខេត្ត | មាន ០៨ បន្ទប់ សំរាប់ចំនេះទូទៅ |

**XII - ខេត្តបន្ទាយមានជ័យ មាន ០៣ មណ្ឌល :**

| | |
|---|---|
| ១–មណ្ឌល វិទ្យាល័យ បន្ទាយមានជ័យ | មាន ៣០ បន្ទប់ សំរាប់ចំណេះទូទៅ |
| ២–មណ្ឌល បឋមសិក្សា ស្វាភី | មាន ១៧ ក្នុងនោះបំពេញវិជ្ជា ០១បន្ទប់ |
| ៣–មណ្ឌល មង្គលបូរី | មាន ៣៥ បន្ទប់ សំរាប់ចំណេះទូទៅ |

**XIII - ខេត្តកំពង់ធំ មាន ០៣ មណ្ឌល**

| | |
|---|---|
| ១–មណ្ឌល វិទ្យាល័យ កំពង់ធំ | មាន ៥១ បន្ទប់ សំរាប់ចំណេះទូទៅ |
| ២–មណ្ឌលវិទ្យាល័យ បល្ល័ង្គ | មាន ២៤ បន្ទប់ សំរាប់ចំណេះទូទៅ |
| ៣–មណ្ឌល អនុវិទ្យាល័យ កំពង់ថ្ម | មាន ១៥ បន្ទប់ សំរាប់ចំណេះទូទៅ |

**XIV - ខេត្តកំពង់កំពង់ចាម មាន ១២ មណ្ឌល និង ០៤ អនុមណ្ឌល**

| | |
|---|---|
| ១–មណ្ឌល វិទ្យាល័យ ព្រះសីហនុ | មាន ៤៦ បន្ទប់ សំរាប់ចំណេះទូទៅ |
| –អនុមណ្ឌល បឋមសិក្សា ទួលថ្ម | មាន ១៥ បន្ទប់ ក្នុងនោះបំពេញវិជ្ជា ០១ បន្ទប់ |
| ២–មណ្ឌល អនុវិទ្យាល័យ ភ្នំប្រុស | មាន ២៤ បន្ទប់ សំរាប់ចំណេះទូទៅ |
| –អនុមណ្ឌល បឋមសិក្សា ភ្នំប្រុស | មាន ០៨ បន្ទប់ សំរាប់ចំណេះទូទៅ |

| | |
|---|---|
| ៣–មណ្ឌល វិទ្យាល័យ ពាមជីកង | មាន ២៦ បន្ទប់ សំរាប់ចំណេះទូទៅ |
| ៤–មណ្ឌល វិទ្យាល័យ ស្ទឹង | មាន ២១ បន្ទប់ សំរាប់ចំណេះទូទៅ |
| ៥–មណ្ឌល វិទ្យាល័យ ព្រៃឈរ | មាន ២១ បន្ទប់ សំរាប់ចំណេះទូទៅ |
| –អនុមណ្ឌលបឋមសិក្សាព្រៃទទឹង | មាន ១០ បន្ទប់ សំរាប់ចំណេះទូទៅ |
| ៦–មណ្ឌល បឋមសិក្សាស្វាយទាប | មាន ២៣ បន្ទប់ សំរាប់ចំណេះទូទៅ |
| ៧–មណ្ឌល វិទ្យាល័យ ត្បូងឃ្មុំ | មាន ៣៩ បន្ទប់ សំរាប់ចំណេះទូទៅ |
| ៨–មណ្ឌល វិទ្យាល័យ ក្រូចឆ្មារ | មាន ១៦ បន្ទប់ សំរាប់ចំណេះទូទៅ |
| ៩–មណ្ឌល អនុវិទ្យាល័យ កណ្ដោលជ្រុំ | មាន ១២ បន្ទប់ សំរាប់ចំណេះទូទៅ |
| ១០–មណ្ឌលវិទ្យាល័យ ៧ មករា | មាន ៩ បន្ទប់ សំរាប់ចំណេះទូទៅ |
| ១១–មណ្ឌលវិទ្យាល័យ ជីហែ | មាន ២៦ បន្ទប់ សំរាប់ចំណេះទូទៅ |
| ១២–មណ្ឌលវិទ្យាល័យ ស្រីសន្ធរ | មាន ២៥ បន្ទប់ សំរាប់ចំណេះទូទៅ |
| –អនុមណ្ឌល បឋមសិក្សាព្រែកពោធិ៍ | មាន ០៩ បន្ទប់ សំរាប់ចំណេះទូទៅ |

**XV - ខេត្តក្រចេះ មាន ០១ មណ្ឌល និង ០៣ អនុមណ្ឌល :**

| | |
|---|---|
| ១–មណ្ឌល វិទ្យាល័យ ព្រះកុសុមៈ | មាន ២៥ បន្ទប់ សំរាប់ចំណេះទូទៅ |
| –អនុមណ្ឌល អនុវិទ្យាល័យ ក្រចេះក្រុង | មាន ១៥ បន្ទប់ សំរាប់ចំណេះទូទៅ |
| –អនុមណ្ឌល បឋមសិក្សា ក្រចេះក្រុង | មាន ០៩ បន្ទប់ សំរាប់ចំណេះទូទៅ |
| –អនុមណ្ឌល បឋមសិក្សា រកាកណ្ដាល | មាន ១១ បន្ទប់ សំរាប់ចំណេះទូទៅ |

**XVI - ខេត្ត សៀមរាប មាន ០៣ មណ្ឌល និង ០៤ អនុមណ្ឌល :**

| | |
|---|---|
| ១–មណ្ឌល សៀមរាប | មាន ១៧ បន្ទប់ សំរាប់ចំណេះទូទៅ |
| –អនុមណ្ឌល អនុវិទ្យាល័យ អង្គរ | មាន ២៥ បន្ទប់ សំរាប់ចំណេះទូទៅ |
| –អនុមណ្ឌល វត្តដំណាក់ | មាន ១២ បន្ទប់ ក្នុងនោះបំពេញវិជ្ជា ០១បន្ទប់ |
| ២–មណ្ឌល ពួក | មាន ១៨ បន្ទប់ សំរាប់ចំណេះទូទៅ |
| –អនុមណ្ឌល ក្រឡាញ់ | មាន ០៩ បន្ទប់ សំរាប់ចំណេះទូទៅ |
| ៣–មណ្ឌល សូទ្រនិគម | មាន ១២ បន្ទប់ សំរាប់ចំណេះទូទៅ |
| –អនុមណ្ឌល ជីក្រែង | មាន ០៩ បន្ទប់ សំរាប់ចំណេះទូទៅ |

**XVII - ខេត្ត ស្ទឹងត្រែង មាន ០១ មណ្ឌល :**

១-មណ្ឌលវិទ្យាល័យ ព្រះរាជបូណ៌យកិច្ច មាន ០៩ បន្ទប់ សំរាប់ចំណេះទូទៅ

**XVIII - ខេត្តកោះកុង មាន ០២ មណ្ឌល :**

១-មណ្ឌលវិទ្យាល័យ កោះកុង មាន ០៥ បន្ទប់ សំរាប់ចំណេះទូទៅ

២-មណ្ឌលអនុវិទ្យាល័យ ស្រែអំបិល មាន ០៣ បន្ទប់ សំរាប់ចំណេះទូទៅ

**XIX - ខេត្ត ព្រះវិហារ មាន ០១ មណ្ឌល :**

១-មណ្ឌល ត្បែងមានជ័យ មាន ០៦ បន្ទប់ សំរាប់ចំណេះទូទៅ

**XX - ខេត្តរតនៈគីរី មាន ០១ មណ្ឌល :**

១-មណ្ឌល វិទ្យាល័យ បានលុង មាន ០៣ បន្ទប់ សំរាប់ចំណេះទូទៅ

**XXI - ខេត្តមណ្ឌលគីរី មាន ០១ មណ្ឌល :**

១-មណ្ឌល អនុវិទ្យាល័យ សង្គមរាស្ត្រនិយម មាន ០១ បន្ទប់ សំរាប់ចំណេះទូទៅ

**ប្រការ ២:** ប្រធានមន្ទីរអប់រំយុវជន និងកីឡា ខេត្តក្រុង និងនាយកគ្រឹស្ថានសិក្សាដែលគ្រឹះស្ថានសិក្សារបស់ខ្លួន ត្រូវយកធ្វើជាមណ្ឌលប្រឡងមានភារកិច្ចរៀបចំមណ្ឌលប្រឡងសៀវភៅកំរងរូបថតបេក្ខជនបញ្ជីផ្សេងៗ និងសំភារៈចាំបាច់សំរាប់ការប្រព្រឹត្តិទៅនៃការប្រឡងអោយហើយស្រេចមុនថ្ងៃបើកសម័យប្រឡង ។

**ប្រការ ៣ :** ប្រធានចំនេះទូទៅ និងមត្តេយ្យសិក្សាប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធប្រធាននាយកដ្ឋានផែនការ និងហិរញ្ញកិច្ចប្រធាននាយកដ្ឋានបុគ្គលិក និងប្រធានមន្ទីរក្រសួងអប់រំយុវជន និងកីឡាមានភារកិច្ចរៀងៗ ខ្លួនអនុវត្តអោយបានសំរេចតាមសេចក្តីប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**តូល ឡោះ**

# ៤-ទីស្ដីការរដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិស្ថាន

**ប្រកាស**

ភ្នំពេញ, ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៩៥

**ប្រកាសលេខ ១០៧២ ចត បស្ថ**

**ស្ដីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ**

រដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិស្ថាន

******

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេច **នរោត្តមសីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាណាចក្រកម្ពុជា លេខ នស.រកត ១០៩៤៨៣ ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៤ ។

-បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩-៧-១៩៩៤ ដែលប្រកាសដោយព្រះរាជក្រមចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤ ។

-យោងពាក្យសុំផ្ទេរ ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ១៩៩៥

-ពិនិត្យលើការចាំបាច់របស់មន្ទីរគ្រប់គ្រងបរិស្ថានរាជធានីភ្នំពេញ ។

**សំរេច**

**ប្រការ ១** :ផ្ទេរភារកិច្ចលោក **សឿន សិទ្ធ** បច្ចុប្បន្នបំរើការងារនៅនាយកដ្ឋានត្រួតពិនិត្យទប់ស្កាត់ និងបន្ថយការបំពុលបរិស្ថានអោយទៅបំរើការងារនៅមន្ទីរគ្រប់គ្រងបរិស្ថានរាជធានីភ្នំពេញ ។

**ប្រការ ២** :ប្រាក់បៀវត្ស និងរបបឧបត្ថម្ភផ្សេងៗ របស់សាមីខ្លួន ត្រូវបានផ្ទេរទៅអង្គភាពថ្មី បន្ទាប់ពីមានវិញ្ញាបនប័ត្រផ្ដាច់ប្រាក់ពីអង្គភាពដើម ។

**ប្រការ ៣** :អគ្គនាយក ខុទ្ទកាល័យ មន្ទីរគ្រប់គ្រងបរិស្ថានរាជធានីភ្នំពេញអង្គភាពដែលពាក់ព័ន្ធ

និងលោក សឿន សិទ្ធ មានភារកិច្ចអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាត
ទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

វេជ្ជ. ស៊ិន សឿម

៥—ទីស្តីការរដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ

**ប្រកាស**

ភ្នំពេញ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ១៩៩៥

**ប្រកាសលេខ ១៣២២ អ ជ ប**

ស្តីពីការតែងតាំងមន្ត្រីរាជការ

រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ របស់ព្រះករុណា ព្រះបាទ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល

–បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការប្រព្រឹត្តិទៅ នៃក្រសួងអភិវឌ្ឍន៍ជនបទ

–បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ស្តីពីការតែងតាំងឯកឧត្តម **ទី ចំរ្នុផល** ជាអនុរដ្ឋលេខាធិការ

–តម្រូវការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

**សំរេច**

**ប្រការ ១** :តែងតាំងលោកស្រី **ឡី ម៉េង** បច្ចុប្បន្នជាប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមអោយ ទទួលបន្ទុកជា អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការបច្ចេកទេស ។

**ប្រការ ២** : រាល់សេចក្តីសំរេចណាដែលផ្ទុយពីប្រកាសនេះ ចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣** : ខុទ្ទកាល័យ អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន គ្រប់មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ក្រុង និងសាម៉ីជនមានភារៈកិច្ចអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**វេជ្ជ.យ៉ុន គឹមហួត**

បោះពុម្ពនៅរោងពុម្ពទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ៤០៦ រៀល